ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខៈ ១៥៨/២៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃពុធ ១រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញថ្ងៃទី០៨ ខែ តុលា ឆ្នាំ២០២៥

# សេចក្តីប្រកាសព័ត៌មាន

## ការចុះបញ្ជីលក់សញ្ញាបណ្ណធម្មតា (សញ្ញាបណ្ណបន្ទាប់បន្សំ) ជាផ្លូវការរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅផ្សារមូលបត្រកម្ពុជា

នាព្រឹកថ្ងៃពុធ ១រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៥ ផ្សារមូលបត្រកម្ពុជា បានរៀបចំ **"ពិធីចុះបញ្ជីលក់សញ្ញាបណ្ណធម្មតា (សញ្ញាបណ្ណបន្ទាប់បន្សំ) ជាផ្លូវការលើកទី២ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី"** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ម៉ៅ សាហ៊ីប** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជាដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា **ឯកឧត្តម ហុង សុម្ភារ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃផ្សារមូលបត្រកម្ពុជា និងតំណាងពីធនាគារជាតិនៃកម្ពុជា។

ថ្លែងក្នុងមតិបើកកម្មវិធី ឯកឧត្តមបណ្ឌិតសភាចារ្យ **ម៉ៅ សាហ៊ីប** បានសំដែងការអបអរសាទរដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចុះបញ្ជីលក់មូលបត្របំណុលជា លើកទី២ ក៏ជាការបង្ហាញពីការតាំងចិត្តយ៉ាងមុតមាំ របស់ថ្នាក់ដឹកនាំនៃធនាគារ ក្នុងការចូលរួមចំណែកអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ហើយការនេះក៏បង្ហាញពីភាពចាស់ទុំ ភាពរឹងមាំនៃផ្សារមូលបត្រកម្ពុជា។ ឯកឧត្តមបណ្ឌិតសភាចារ្យ មានប្រសាសន៍បន្ថែមទៀតថា ផ្សារមូលបត្រកម្ពុជា មិនត្រឹមតែបានបង្កើតនូវជម្រើសហិរញ្ញប្បទានដ៏សម្បូរបែប និងអនុញ្ញាតឱ្យក្រុមហ៊ុនចុះបញ្ជី មានលទ្ធភាពក្នុងការកៀរគរទុនបានច្រើនដងច្រើនលើក ផងដែរ។ ឯកឧត្តមបណ្ឌិតសភាចារ្យបានគូសរំលេចថា ក្រោមការដឹកនាំដ៏ស្វាហាប់ និង ប៉ិនប្រសប់ប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានដាក់ចេញនៅ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ក្នុងដំណើរឈានទៅសម្រេចឱ្យបាននៅ **ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលខ្ពស់ នៅឆ្នាំ២០៥០** ដោយបន្តយកចិត្តទុកដាក់ខ្ពស់លើវិស័យមូលបត្រ តាមរយៈការជំរុញការធ្វើនវានុវត្តយន្តការហិរញ្ញប្បទាន និង ផលិតផលហិរញ្ញវត្ថុ សំដៅគាំទ្រដល់ការវិនិយោគ និង ការធ្វើពិពិធកម្មសេដ្ឋកិច្ច។

ថ្លែងក្នុងមតិអបអរសាទរ ឯកឧត្តម **ស៊ូ សុជាតិ** បានសម្តែងការអបអរសារទរដល់ធនាគារអេស៊ីលីដាដែលជាធនាគារពាណិជ្ជមួយគត់ ដែលបានសម្រេចនូវការបោះផ្សាយទាំងមូលបត្រកម្មសិទ្ធិ កាលពីខែឧសភា ឆ្នាំ២០២០ កន្លងទៅ និងមូលបត្របំណុលចំនួន២លើកក្នុងឆ្នាំ២០២៥នេះ ដែលទឹកប្រាក់កៀរគរសរុបចំនួន ២០០លានដុល្លារអាមេរិក។ ឯកឧត្តម ក៏បានបញ្ជាក់ទៀតថា ឆ្នាំនេះនឹងក្លាយជាឆ្នាំជោគជ័យមួយទៀត ដែលយើងមានកំណើនសាច់ប្រាក់

ដែលកៀរគរសរុបពី ៤០០ លានដុល្លារ កើនឡើងទៅដល់ ៧០០ លានដុល្លារ ដែលកំណើននេះឡើងប្រមាណជិត ១០០ ភាគរយធៀបនឹងឆ្នាំ ២០២៤ បើគិតទៅដល់ចុងឆ្នាំ២០២៥នេះ។

ក្នុងកម្មវិធីនេះផងដែរ ឯកឧត្តម **ហុង សុហួរ** ថ្លែងនូវការទទួលស្វាគមន៍ជាថ្មីម្តងទៀតនូវវត្តមានរបស់ធនាគារ អេស៊ីលីដា ក្នុងការចុះបញ្ជីលក់សញ្ញាបណ្ណបន្ទាប់បន្សំ។ ជាមួយគ្នានេះដែរ ឯកឧត្តមបានគូសបញ្ជាក់ថាវិស័យមូលបត្រ និងវិស័យធនាគារជាវិស័យបំពេញឱ្យគ្នា សម្រាប់សហគ្រាស ក្នុងការទទួលបានប្រភពហិរញ្ញប្បទានសម្រាប់ពង្រីកអាជីវកម្ម និងជួយជំរុញសកម្មភាពសេដ្ឋកិច្ចឱ្យរីកចម្រើនប្រកបដោយចីរភាព។

ឯកឧត្តមក៏បានបន្ថែមថា សកម្មភាពទីផ្សារមានកំណើនគួរអោយកត់សំគាល់ នៅថ្ងៃនេះដែរ ផ្សារមូលបត្របានបង្កើតនូវកំណត់ត្រាថ្មីមួយទៀតដោយជួយកៀរគរទុនជូនធនាគារ អេស៊ីលីដា បានរហូតដល់ទៅ ២០០ លានដុល្លារ ដូចទៅនឹងប្រសាសន៍របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** បញ្ជាក់ថា **ទីផ្សារមូលបត្រគឺជាប្រភពទុនមិនចេះរីងស្ងួត**។ នេះសបញ្ជាក់ឱ្យឃើញថា**ទី១** ផ្សារភាគហ៊ុនកំពុងក្លាយជាកន្លែងដែលផ្តល់នូវប្រភពទុនមួយសំខាន់ដល់ធនាគារពាណិជ្ជក្នុងការបំពេញនូវតម្រូវការរបស់ខ្លួនបន្ថែមលើប្រភពហិរញ្ញប្បទានដទៃទៀតដែរបានប្រើប្រាស់កន្លងមក ។ **ទី២** បង្ហាញឱ្យឃើញថាធនាគារ អេស៊ីលីដា ទទួលបានការជឿជាក់ និងទំនុកចិត្តខ្ពស់ពីសំណាក់ វិនិយោគិនគុណវុឌ្ឍិទាំងរូបវន្តបុគ្គល និងនីតិបុគ្គល។

ក្នុងឱកាសនេះ លោក **អែម កំណាន់** បានបង្ហាញនៅការអបអរសាទរ និងកោតសរសើរ ក្នុងការចុះបញ្ជីលក់សញ្ញាបណ្ណបន្ទាប់បន្សំរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ការចុះបញ្ជីលក់សញ្ញាបណ្ណនេះជួយដល់ធនាគារពង្រឹងស្ថានភាពដើមទុន និងបង្កើនសមត្ថភាពផ្តល់ឥណទាន ដោយរក្សាបានអនុលោមភាព តាមស្តង់ដារត្រួតពិនិត្យប្រកបដោយការប្រុងប្រយ័ត្នខ្ពស់។ លោកបានបន្ថែមផងដែរថា ការចូលរួមរបស់ធនាគារក្នុងវិស័យមូលបត្រជាជំហានវិជ្ជមានមួយឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុមួយដែលមានភាពស៊ីជម្រៅ និងភាពធន់ ដោយការបោះផ្សាយមានរយៈពេលវែងឆ្លុះបញ្ចាំងអំពីនិរន្តរភាពហិរញ្ញវត្ថុ និងការយកចិត្តទុកដាក់ចំពោះពិពិធកម្មប្រភពហិរញ្ញប្បទាន។

ក្រោមមតិស្វាគមន៍ បណ្ឌិត **អ៊ុន ចាន់នី** បានបញ្ជាក់ថា ការកៀរគរទុនតាមរយៈទីផ្សារមូលបត្រកម្ពុជា ទាំងការបោះផ្សាយមូលបត្រកម្មសិទ្ធិ និងសញ្ញាបណ្ណបន្ទាប់បន្សំ បានអនុញ្ញាតឱ្យធនាគារទទួលបាននូវប្រភពហិរញ្ញប្បទានដ៏រឹងមាំមួយ។ការណ៍នេះ បានផ្តល់ឱកាសជូនវិនិយោគិន និងជួយធនាគារក្នុងការប្រមូលប្រភពទុនរយៈពេលវែង សម្រាប់គាំទ្រប្រតិបត្តិការធនាគារ បង្កើនទំនុកចិត្តពីវិនិយោគិន និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក និងសង្គមជាតិ។

Cambodia Securities Exchange

**ផ្សារមូលបត្រកម្ពុជា**

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង÷
នាយកដ្ឋានចុះបញ្ជី និងផ្តល់ព័ត៌មាន
អ៊ីម៉ែល÷ listing@csx.com.kh